ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ACCOUNTING AND AUDITING REGULATOR

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.........✓...........ន. គ. ស .......

ថ្ងៃព្រហ. ៨ កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កក្កដា គ.ស.២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តវិធានទប់ស្កាត់ការវាយប្រហារសាយប័រ

**និយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស.)នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.)** សូមជម្រាបជូន ម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ(អង្គភាព) ជ្រាបថា៖ ដោយមានការវាយប្រហារសាយប័រមកលើវេបសាយ និងប្រព័ន្ធអនឡាញមួយចំនួនក្នុងប្រទេសកម្ពុជា ក្នុងការលួចយកគណនីរបស់អ្នកប្រើប្រាស់ តាមរយៈវិធីសាស្ត្របោកបញ្ឆោត(Phishing)ដោយប្រើប្រាស់អ៊ីម៉ែល ឬប្រព័ន្ធទំនាក់ទំនងសង្គមដូចជា តេឡេក្រាម(Telegram), វ៉ាតអេប (WhatsApp) និង សារ (Messenger) ជាដើម ដើម្បីឱ្យអ្នកប្រើប្រាស់ចុចបើកទៅលើតំណភ្ជាប់ (Link) និងផ្លាស់ប្តូរពាក្យសម្ងាត់ ហើយក្រុមហេគឃ័រ (Hacker) នឹងធ្វើការគ្រប់គ្រងទាំងស្រុងទៅលើគណនីប្រើប្រាស់នេះ ហើយក៏អាចមានលទ្ធភាពក្នុងការជ្រៀតចូលទៅកាន់កុំព្យូទ័រផ្សេងទៀត នៅក្នុងបណ្តាញតែមួយផងដែរ។

ដូច្នេះ ដើម្បីការពារពីការលួចគ្រប់គ្រង និងកាន់កាប់គណនីរបស់អ្នកប្រើប្រាស់ប្រព័ន្ធ E-Filing System ក៏ដូចជាថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល **ន.គ.ស.** សូមដាក់ចេញនូវការអនុវត្តវិធានទប់ស្កាត់ការវាយប្រហារសាយប័រ ដោយការពង្រឹងការអនុវត្តសន្តិសុខការពារប្រព័ន្ធ ការពារគណនី និងថ្នាលឌីជីថល តាមរយៈមុខងារសុវត្ថិភាពចាក់សោពីរជាន់ (Two-Factor Authentication)។

ក្នុងន័យនេះ **ន.គ.ស.** សូមធ្វើការណែនាំដល់សហគ្រាស និងអង្គភាព ត្រូវអនុវត្តវិធានការសន្តិសុខ ដូចខាងក្រោម៖

- ផ្លាស់ប្តូរពាក្យសម្ងាត់គណនីប្រើប្រាស់ប្រព័ន្ធ E-Filing System ក៏ដូចជាថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថលឡើងវិញដោយប្រើប្រាស់ពាក្យសម្ងាត់ដែលមានកម្រិតសុវត្ថិភាពខ្ពស់ (មានលេខ អក្សរ និងនិមិត្តសញ្ញា) និងត្រូវផ្លាស់ប្តូរពាក្យសម្ងាត់ឱ្យបានរួចរាល់មុន **ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥** ដើម្បីអាចអនុវត្តកាតព្វកិច្ចនានាបានទាន់ពេលកំណត់។
- មុននឹងចូលប្រើប្រាស់គេហទំព័ររបស់ **ន.គ.ស.** URL (https://www.acar.gov.kh/) ត្រូវពិនិត្យមើលឱ្យបានច្បាស់ ជៀសវាងរាល់សារ និងតំណភ្ជាប់ដែលទទួលបានពីប្រភពដែលមិនស្គាល់។

ករណីមានការផ្លាស់ប្តូរ ឬភ្លេចអ៊ីម៉ែលប្រើប្រាស់ក្នុងប្រព័ន្ធ E-Filing System សហគ្រាស ឬអង្គភាពត្រូវស្នើសុំផ្លាស់ប្តូរគណនីប្រើប្រាស់ក្នុងប្រព័ន្ធ E-Filing System ដោយត្រូវដាក់ពាក្យស្នើសុំមក **ន.គ.ស.** ដោយផ្ទាល់ ដើម្បីអាចអនុវត្តមុខងារសុវត្ថិភាពចាក់សោពីរជាន់ (Two-Factor Authentication) និងត្រូវបង់កម្រៃសេវា អនុលោមតាមប្រកាសលេខ០០២ អ.ស.ហ.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាព ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**និយ័តករគណនេយ្យនិងសវនកម្ម**

ដើម្បីទទួលបាន ឬសាកសួរព័ត៌មាន
អំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់ ន.គ.ស